# ការធ្វើដំណើរទៅកាន់ទីតាំងចាក់ថ្នាំបង្ការជំងឺ COVID-19

***មីនា 2021***

ឥឡូវនេះ យើងមានជម្រើសច្រើនក្នុងការធ្វើដំណើរសម្រាប់អ្នករស់នៅក្នុងរដ្ឋមេន ដែលត្រូវការប្រើប្រាស់មធ្យោបាយធ្វើដំណើរទៅកាន់ទីតាំងចាក់ថ្នាំបង្ការជំងឺ COVID-19 តាមណាត់ និងត្រឡប់មកផ្ទះវិញ ។ យើងខ្ញុំមានផ្តល់ជូនមធ្យោបាយធ្វើដំណើរដោយឥតគិតថ្លៃ សម្រាប់ពលរដ្ឋ ដែលខ្វះមធ្យោបាយធ្វើដំណើរគួរឲ្យទុកចិត្តបាន អ្នកមិនចេះ បើកបរ ឬអ្នកមិនអាចធ្វើដំណើរទៅកាន់ទីតាំងចាក់ថ្នាំបង្ការដោយខ្លួនឯង ។

## ជម្រើសមធ្យោបាយធ្វើដំណើរ

**ការធ្វើដំណើរក្រៅគ្រាអាសន្នរបស់ MaineCare**
បើអ្នកជាសមាជិករបស់ MaineCare ដែលប្រើប្រាស់ សេវាកម្មធ្វើដំណើរ មិនស្ថិតក្នុងស្ថានភាពគ្រាអាសន្ន តាមរយៈអន្តរការី ដើម្បីរៀបចំមធ្យោបាយធ្វើដំណើរទៅទទួល សេវាកម្មដែលស្ថិតក្រោមការធានារ៉ាប់រងពី MaineCare របស់អ្នក សូមហៅទូរស័ព្ទ ជួបជាមួយអន្តរការីនោះដដែល ដើម្បីស្នើសុំមធ្យោបាយធ្វើដំណើរទៅកាន់ទីតាំងចាក់ថ្នាំបង្ការជំងឺនេះតាមការណាត់ ។ អ្នកត្រូវរៀបចំណាត់ពេលវេលាចាក់ថ្នាំបង្ការឲ្យបានរួចរាល់ មុនស្នើសុំមធ្យោបាយធ្វើដំណើរ ហើយអ្នកត្រូវស្នើសុំមធ្យោបាយធ្វើដំណើរ យ៉ាងហោចណាស់ 48 ម៉ោង មុនពេលណាត់ចាក់ថ្នាំបង្ការរបស់អ្នកមកដល់ ។

**ការធ្វើដំណើរមកចាក់ថ្នាំបង្ការជំងឺរបស់សមាជិក ModivCare**
ជម្រើសនេះគឺមានផ្តល់ជូន ចំពោះពលរដ្ឋរបស់រដ្ឋមេន ដែលមិនមានលទ្ធភាពទទួលបានមធ្យោបាយធ្វើដំណើរដែលគួរឲ្យទុកចិត្តបាន ដោយបូករួមទាំងសមាជិក MaineCare ដែលមិនមានសិទ្ធិអាចទទួលបានសេវាកម្មធ្វើដំណើរក្រៅគ្រាអាសន្ន ។

មធ្យោបាយធ្វើដំណើរ គឺមានផ្តល់ជូនចំពោះអ្នកដែលបានណាត់ពេទ្យចាក់ថ្នាំបង្ការជំងឺក្នុងរវាងម៉ោងពី 7:00នាទីព្រឹកដល់ម៉ោង 4:00នាទីល្ងាច ។ ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ។ អ្នកត្រូវធ្វើការណាត់ពេលចាក់ថ្នាំបង្ការជំងឺឲ្យបានរួចរាល់សិន សឹមស្នើសុំមធ្យោបាយធ្វើដំណើរ ។ ដើម្បីរៀបចំណាត់ពេលធ្វើដំណើរទៅចាក់ថ្នាំបង្ការជំងឺ សូមហៅទូរស័ព្ទមកកាន់ Modivcare តាមលេខ **1-855-608-5172** ឲ្យបានយ៉ាងហោចណាស់ 48 ម៉ោង មុនពេលដែលអ្នកត្រូវធ្វើដំណើរមកទទួលថ្នាំបង្ការ ។

សូមចងចាំទុកថា មធ្យោបាយធ្វើដំណើរបែបនេះ គឺមិនមានផ្តល់ជូនសម្រាប់ទីតាំងចាក់ថ្នាំបង្ការដែលអាចបើកឡានចូលឡើយ ។

## ការត្រៀមខ្លួនធ្វើដំណើរ

បើអ្នកនឹងប្រើជម្រើសមធ្យោបាយធ្វើដំណើរណាមួយ ដែលមានផ្តល់ជូន សូមចងចាំទុកនូវចំណុចនីមួយៗខាងក្រោម ៖

- ពេលអ្នកហៅទូរស័ព្ទស្នើសុំមធ្យោបាយធ្វើដំណើរ គឺអ្នកត្រូវប្រាប់អ្នកផ្តល់សេវាកម្មនូវកាលបរិច្ឆេទ និងម៉ោងពេលដែលទទួលថ្នាំបង្ការ ដែលបានណាត់ទុកព្រមទាំងឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់មណ្ឌលចាក់ថ្នាំបង្ការរបស់អ្នក ។
- មធ្យោបាយធ្វើដំណើរនឹងមានផ្តល់ជូនក្នុងការធ្វើដំណើរទៅកាន់ទីតាំងចាក់ថ្នាំបង្ការ និងត្រឡប់មកផ្ទះវិញ ។
- អ្នកអាចធ្វើដំណើររួមជាមួយអ្នកដទៃ ដើម្បីឲ្យ DHHS អាចមានលទ្ធភាពផ្តល់ជំនួយដល់អ្នកគ្រប់គ្នាដែលខ្វះខាតមធ្យោបាយធ្វើដំណើរ ។
- អ្នកត្រូវពាក់ម៉ាស់ ។
- អ្នកត្រូវត្រៀមខ្លួនឲ្យបានរួចរាល់ ចាំឡានមកទទួលយ៉ាងហោចណាស់ 30 នាទី មុន រហូតដល់ 15 នាទីក្រោយម៉ោងដែលឡានត្រូវមកយកអ្នក តាមការណាត់ ។
- អ្នកបើកបរនឹងយកអ្នកទៅដាក់ត្រង់ទីតាំងចាក់ថ្នាំបង្ការ ហើយគេនឹងមកយកអ្នកត្រឡប់ទៅផ្ទះវិញប្រហែលជា 60នាទី ក្រោយម៉ោងណាត់ចាក់ថ្នាំបង្ការរបស់អ្នក ។
- យើងខ្ញុំនឹងហៅទូរស័ព្ទទៅអ្នក មួយថ្ងៃមុនការចេញដំណើរ ដើម្បីរំឭកអ្នកអំពីការធ្វើដំណើរដែលអ្នកបានស្នើសុំ ។

សម្រាប់ព័ត៌មានបន្ថែមអំពីការណាត់ជួបពេទ្យ ដើម្បីចាក់ថ្នាំបង្ការ សូមចូលមកកាន់ www.maine.gov/covid19/vaccines/vaccination-sites ឬហៅទូរស័ព្ទទៅកាន់ទូរស័ព្ទសហគមន៍រដ្ឋមេន សម្រាប់ចាក់ថ្នាំបង្ការជំងឺ COVID-19 (Maine COVID-19 Community Vaccine Line) តាមលេខ 1-888-445-4111 ។ (បើអ្នកត្រូវការសេវាកម្មបកប្រែភាសា សូមប្រាប់ឈ្មោះភាសារបស់អ្នក ពេលការីទូរស័ព្ទឆ្លើយទូរស័ព្ទរបស់អ្នក ។ ចំពោះមនុស្សថ្លង់ ឬអ្នកពិបាកស្តាប់ សូមហៅទូរស័ព្ទមកលេខ 711 ហើយស្នើសុំភ្ជាប់ទៅលេខ 1-888-445-4111)

ដើម្បីស្នើសុំឯកសារនេះ ក្នុងទម្រង់ផ្សេង សូមហៅទូរស័ព្ទមកលេខ (207) 287-5014 ។ ចំពោះអ្នកថ្លង់ ឬពិបាកស្តាប់ សូមហៅទូរស័ព្ទមកលេខ 711 (លេខសម្រាប់បញ្ជូនបន្តរបស់រដ្ឋមេន) ឬផ្ញើអ៊ីម៉េលមកកាន់ ADA-Civilrights.dhhs@maine.gov